**គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា (គ.ប.ស.យ)**
Committee For Free And Fair Elections In Cambodia (COMFREL)
ទីស្នាក់ការកណ្តាល ផ្ទះលេខ ១៣៨ ផ្លូវ ១២២ សង្កាត់ទឹកល្អក់ ១ ខ័ណ្ឌទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
Central Office: #138, St. 122, Teuk Laak I, Tuol Kork, Phnom Penh, CAMBODIA.
ខុមហ្វ្រែល COMFRE P.O. Box 1145, Tel: (855) 23 884 150/12 942 019, Fax: (855) 23 883 750 E-mail: comfrel@online.com.kh, comfrel@comfrel.org or comfreladmin@online.com.kh, Site : www.comfrel.org

**គណៈកម្មាធិការនាយក**
**BOARD OF DIRECTORS**

លោក **ធន សារាយ**
**Mr. THUN SARAY**
ប្រធានគណៈកម្មាធិការនាយក
និងជាប្រធាន **ADHOC**

លោក **សុក សំអឿន**
**Mr. SOK Sam Oeun**
អនុប្រធានគណៈកម្មាធិការនាយក
និងជានាយក **CDP**

លោក **យឹម ប៉ូ**
**Mr. YIM Po** អគ្គលេខាធិការ
និង នាយក **CCPCR**

កញ្ញា **ស៊ុន ចាន់សែន**
**Miss. SUN Chansen**
ប្រធាន **KYA**

លោក **មុំ សារិន**
**Mr. MOM Sarin**
នាយក **HRCDO**

លោកស្រី **ពឹង យក់ហៀប**
**Ms. PEUNG Yok Hiep**

លោកស្រី **ទិវ សារាយេត**
**Ms. TIV Sarayet**
សហនាយិកា **WMC**

កញ្ញា **សយ សារា វឌ្ឍនី**
**Miss. SAY Sara Vathany**
នាយិកា **CWCC**

លោក **គីម សុវណ្ណ**
**Mr. KIM Sovann**
នាយក **VIGILANCE**

លោក **អាង ច័ន្ទឫទ្ធិ**
**Mr. ANG Chanrith**
នាយក **KKKHRO**

លោក **យង់ គិមអេង**
**Mr. YONG Kim Eng**
នាយក **PDP-Center**

លោក **ភួង សិទ្ធិ**
**Mr. PHUONG Sith**

លោក **សឺន សែត**
**Mr. SEN Set**

ស.ប្រ.ក.៣/លេខ ០៧/០៩ គ.ប.ស.យ/អ.ក

# សេចក្តីប្រកាសព័ត៌មាន

## ស្តីពី

## លទ្ធផលសិក្ខាសាលាម្ចាស់ឆ្នោតក្នុងការកំណត់លក្ខខណ្ឌសន្ទស្សន៍[១] នៃវិស័យអាទិភាព ក្នុងខេត្ត ស្វាយរៀង

*ភ្នំពេញ, ថ្ងៃទី ២២ ខែ មិថុនា ឆ្នាំ ២០០៩*

ប្រជាពលរដ្ឋប្រមាណ ៨០នាក់ មកពីស្រុកស្វាយទាប ស្រុកចន្ទ្រា ស្រុករមាសហែក ស្រុករំដួល ស្រុកស្វាយជ្រុំ និងក្រុងស្វាយរៀង នៅក្នុងខេត្តស្វាយរៀង និងមានសិក្ខាកាមស្ត្រីចូលរួមប្រមាណ១៨% បានជួបជុំគ្នានៅក្នុងសិក្ខាសាលា ម្ចាស់ឆ្នោតក្នុងការកំណត់លក្ខខណ្ឌសន្ទស្សន៍នៃវិស័យអាទិភាពក្នុងខេត្តស្វាយរៀង ។

អគ្គលេខាធិការសាលាខេត្តស្វាយរៀង លោក ចាន់ សាវ៉ាន់ បានថ្លែងបើកសិក្ខាសាលាបានវាយតម្លៃថា សិក្ខាសាលានេះបានផ្តល់ឱកាសដល់ម្ចាស់ឆ្នោតធ្វើការបង្ហាញពីតម្រូវការរបស់ខ្លួនដល់មន្ត្រីជាប់ឆ្នោត។

ជាលទ្ធផលម្ចាស់ឆ្នោតបានពិភាក្សាកំណត់លក្ខខណ្ឌសន្ទស្សន៍នៃវិស័យអាទិភាពទាំង ១០ ក្នុងខេត្តស្វាយរៀង ដូចខាងក្រោម:

| **លក្ខខណ្ឌសន្ទស្សន៍នៃវិស័យអទិភាពទាំងដប់នៅក្នុងខេត្ត ស្វាយរៀង** |
|---|
| ១) សុំប្រព័ន្ធធារាសាស្ត្រដើម្បីធ្វើស្រូវប្រាំង និងស្រូវវស្សារចំនួន ២ខ្សែ។ ប្រព័ន្ធបង្ហូរទឹកទី១ ចាប់ពីទន្លេវៃគោ ឃុំកំពង់ចកទៅឃុំពងទឹកប្រហែល ៥០០០ម៉ែត្រ ទំហំ ១៥ម៉ែត្រ មាត់លើជំរៅ ៤ម៉ែត្រ និទី២ ចាប់ពីកំពង់ត្រាចមក ម៉ឺនជ័យប្រវែង ១៨គម មាត់លើ ១២ម៉ែត្រ ជំរៅ ៤ម៉ែត្រ ចាប់ផ្តើមពីឆ្នាំ ២០១០ នឹងបញ្ចប់នៅឆ្នាំ ២០១២។ |
| ២) សុំប្រព័ន្ធភ្លើងអគ្គិសនី ចាប់ពីប្រជុំជន ដល់ជនបទ (ចាប់ពីផ្សារជីភូ ដល់ផ្សារកំពង់ចក កាត់តាមឃុំច្រកម្ទេស ឃុំពពែត ឃុំព្រៃតាអី ឃុំគគីរសោម ឃុំស្វាយរំពារ) ដោយគិតតម្លៃសេវា ៤៥០រៀល ក្នុង ១គីឡូវ៉ាត់ម៉ោង ចាប់ពីឆ្នាំ២០០៩ រហូតដល់ឆ្នាំ ២០១០ ឱ្យបានប្រើប្រាស់ និង ចាប់ពីផ្សារជីភូ ដល់ទីរួមស្រុកចន្ទ្រា កាត់តាមឃុំព្រៃអង្គុញ ឃុំព្រៃគគីរ និងឃុំមេសថ្ងក មានប្រវែង ១៥គម ចាប់ពីឆ្នាំ២០០៩ បញ្ចប់ ឆ្នាំ២០១០។ |

[១] ការសន្យាណាដែលមានសូចនាករច្បាស់លាស់-អាចមានជាក់ស្តែង អាចវាស់បានដូចជាការអនុម័តច្បាប់ ការបង្កើតស្ថាប័ន ឬជាសកម្មភាព ការអនុវត្តអ្វីមួយច្បាសលាស់ ដោយមានគោលដៅ ពេលវេលា ឬមានចំនួនកំណត់ច្បាស់លាស់ ឬមួយប្រៀបធៀបទៅនឹងអត្រាណាមួយច្បាស់លាស់។

| |
|---|
| ៣) សុំវគ្គបណ្តុះបណ្តាលបច្ចេកទេសកសិកម្ម ដំណាំស្រូវ ចិញ្ចឹមសត្វ (ដូចជា ជ្រូក មាន់ ទា...) ចិញ្ចឹមត្រី ដាំបន្លែ ជីកស្រះ ធ្វើជីធម្មជាតិ ទាំង ៦ស្រុក ឱ្យបាន ៣ដង ក្នុង ១ឆ្នាំ ចាប់ពី ២០០៩តទៅ។ សុំរាជរដ្ឋាភិបាលជួយ រកទីផ្សារ និងធានាតម្លៃ ផលិតផលកសិកម្ម ចាប់ពីឆ្នាំ២០០៩។ |
| ៤) សុំអោយរាជរដ្ឋាភិបាលកំណត់តំលៃទំនិញលើទីផ្សារ (ជីគីមី ប្រេងឥន្ធនៈ ទំនិញសព្វសារពើ..) ជីគីមីគុណភាពខ្ពស់ តំលៃខ្ពស់ ៨០០០០រៀលមួយបាវ (៥០គក) ប្រេងសាំង ២៥០០រៀល ប្រេងម៉ាសូត ២០០០រៀល និងធ្វើអោយបាន ចាប់ពីឆ្នាំ២០០៩។ |
| ៥) សុំអោយខាងផ្នែកមន្ទីរសុខាភិបាល ជួយពង្រឹងគ្រូពេទ្យឱ្យគោរពតាមក្រមសីលធម៌ ចំពោះអ្នកជំងឺ (កុំឱ្យមានការរើសអើង) ចំពោះអ្នកជំងឺ។ កំណត់តំលៃព្យាបាលឱ្យចុះជាង តម្លៃបច្ចុប្បន្ន ៥០% នៅគ្រប់មណ្ឌលសុខភាព និងមន្ទីរពេទ្យ នៅខេត្តស្វាយរៀងទាំងមូល អោយបាននៅឆ្នាំ២០១០។ |
| ៦) សុំឱ្យមន្ទីរកសិកម្មខេត្ត ជួយបណ្តុះបណ្តាលធ្វើជីធម្មជាតិ និងត្រួតពិនិត្យជីគីមី ដែលធ្វើឱ្យខូចគុណភាពដី និងនាំឱ្យបាត់ទិន្នផលស្រូវ និងបាត់បង់ជីវចំរុះ នៅទូទាំងខេត្ត ចាប់ពីឆ្នាំ២០០៩ តទៅ និងតំរោងត្រូវត្រួតពិនិត្យគុណភាពដីអោយបាន គ្រប់ដីកសិកម្មក្នុង ០១ឆ្នាំ ២ដង។ |
| ៧) សុំឱ្យស្ថាប័នមានសមត្ថកិច្ច (គណៈកម្មការសុរិយោដី និងតុលាការ) ជួយសំរួលដីទំនាស់ឱ្យបានសមស្របដល់ប្រជាពលរដ្ឋក្រីក្រ ដែលខ្វះដីបង្កបង្កើនផល មានដូចជា ស្រុករមាសហែក ចន្ទ្រា រំដួល ស្វាយទាប កំពង់រោទិ៍ និងបាវិត ឱ្យបាន ១០០% ក្នុងឆ្នាំ ២០១៣ ។ |
| ៨) កសាងផ្លូវជាតិថ្មីលេខ១៣ ក្រាលកៅស៊ូចាប់ពីភូមិក្រូច ឃុំជ្រុងពពេល ស្រុករំដួលទៅកាន់ទីរួមស្រុករមាសហែក ប្រហែល ២៥គីឡូម៉ែត្រ និងស្ពានសំរោង ទទឹង ៨ម៉ែត្រ បណ្តោយ ៣០ម៉ែត្រ សង់អំពីថ្មចាក់បេតុង។ សុំកសាងស្ពាន ចុងអូរ ភូមិចុងអូរ ឃុំត្រពាំងស្រាច ទំហំទទឹង ៨ ម៉ែត្រ បណ្តោយ ១០ម៉ែត្រ សង់អំពីថ្ម ចាក់បេតុង អោយហើយចាប់ពីឆ្នាំ២០០៩ និងបញ្ចប់ឆ្នាំ២០១១ ។ |
| ៩) ជួសជុលផ្លូវជាតិពីផ្សារជីភូ ដល់ព្រំដែន ឃុំទួលស្ដី មានទទឹង ១០ម បណ្តោយ ៣៥គម ក្រាលកៅស៊ូ ស្ពានមានចំនួន ០២: ស្ពានទី១ ស្ពានតាអឹម នៅក្នុងភូមិដីក្រហម ឃុំមេសថ្ងក ស្រុកចន្ទ្រា ទទឹង ៨ម និងបណ្តោយ ១២ម ធ្វើអំពីថ្មចាក់បេតុង។ ស្ពានទី២: ស្ពានដូនទៃ ឃុំទួលស្ដី ទទឹង ៨ម បណ្តោយ ១៥ម និងលូ ២៥កន្លែង មុខកាត់ ០១ម ទទឹងថ្នល់ ១០ម ធ្វើចាប់ពីឆ្នាំ២០០៩ ឱ្យហើយនៅឆ្នាំ២០១១។ |
| ១០) សុំអោយសភាអនុម័តច្បាប់ប្រឆាំងអំពើពុករលួយ អោយបានក្នុងឆ្នាំ២០១០។ |

សិក្ខាសាលានេះត្រូវបានរៀបចំឡើងដោយ គណៈកម្មាធិការខុមហ្វ្រែល សហការជាមួយអង្គការសហការដើម្បីអភិវឌ្ឍន៍នៅកម្ពុជា (PADEK) និងអង្គការជំនួយជនបទ (RAO) មជ្ឈមណ្ឌលប្រជាពលរដ្ឋដើម្បីអភិវឌ្ឍន៍ (PDP) បណ្តាញតស៊ូមតិខេត្តស្វាយរៀង (NACN) ដែលក្នុងនោះមានការចូលរួមពីម្ចាស់ឆ្នោតដែល តំណាងអោយសហគមន៍ព្រៃឈើ ដីធ្លី....និងអង្គការមិនមែនរដ្ឋាភិបាលនានា អាជីវករ/ពាណិជ្ជករ មន្ត្រីរាជការ សិស្ស/ និស្សិត កសិករ ។

សិក្ខាសាលាម្ចាស់ឆ្នោតនេះ ជាគំនិតបង្កើតថ្មីមួយក្នុងគោលបំណងឱ្យប្រជាពលរដ្ឋដែលជាម្ចាស់ឆ្នោតនៅតាមមណ្ឌលនីមួយៗ:

១) មានការយល់ដឹងពីកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលជាប់ឆ្នោតឆ្នាំ ២០០៨

២) ចូលរួមក្នុងការកំណត់លក្ខខណ្ឌសន្ទស្សន៍នៃវិស័យអាទិភាពនានា ដែលត្រូវការចាំបាច់ក្នុងមណ្ឌល (ខេត្ត) របស់ខ្លួន

៣) និង លក្ខខណ្ឌសន្ទស្សន៍នៃវិស័យអាទិភាពនានាសម្រាប់មណ្ឌលនីមួយៗ ត្រូវបានចងក្រងជារបាយការណ៍ ដែលអាចឱ្យសិក្ខាកាមងាយចងចាំដើម្បីចូលរួមតាមដាន និងជម្រុញការអនុវត្តរបស់រាជរដ្ឋាភិបាល អ្នក-តំណាងរាស្ត្រ ក្រុមប្រឹក្សា/គណៈអភិបាលខេត្ត-រាជធានី ក្នុងការសម្រេចបានលក្ខខណ្ឌសន្ទស្សន៍នៃវិស័យ ទាំងនោះ។

*សម្រាប់ព័ត៌មានបន្ថែមៗសូមទាក់ទង:*

- លោក **គឹម ឈុន** អ្នកសម្របសម្រួលជាន់ខ្ពស់នៃកម្មវិធីខុមហ្វ្រែល ទូរស័ព្ទ: ០១២ ៩៤២ ០១៩
- លោក **សុខ ពិទូរ្យ** អ្នកសម្របសម្រួលស្តីទីផ្នែកអង្កេតខុមហ្វ្រែល ទូរស័ព្ទ: ០៨៩ ៥២៥ ៤៤៦